អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៩

# សេចក្តីប្រកាសព័ត៌មាន

## អង្គបុរេជំនុំជម្រះនឹងបើកសវនាការស្តាប់ទឡ្ហីករណ៍ពីភាគីនៅក្នុងសំណុំរឿង ០០៣

អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានទទួលបណ្តឹងឧទ្ធរណ៍ដាក់ដោយសហព្រះរាជអាជ្ញាជាតិនៅថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៩ បណ្តឹងឧទ្ធរណ៍ដាក់ដោយសហមេធាវីការពារក្តីឱ្យមាស មុត នៅថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៩ ប្រឆាំងនឹងដីកាដំណោះស្រាយដែលចេញដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិនៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ នៅក្នុងសំណុំរឿង ០០៣ និងបណ្តឹងឧទ្ធរណ៍ដាក់ដោយសហព្រះរាជអាជ្ញាអន្តរជាតិ នៅថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៩ ប្រឆាំងនឹងដីកាលើកលែងចោទប្រកាន់លើមាស មុត ដែលចេញដោយសហចៅក្រមស៊ើបអង្កេតជាតិនៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ នៅក្នុងសំណុំរឿង ០០៣។

អង្គបុរេជំនុំជម្រះបានសម្រេចថា សវនាការនឹងត្រូវធ្វើឡើងនៅក្នុងសំណុំរឿង ០០៣ ដើម្បីស្តាប់ទឡ្ហីករណ៍ពីភាគីនៅក្នុងសំណុំរឿងមុនពេលដែលអង្គបុរេជំនុំជម្រះចេញសាលដីកាលើបណ្តឹងឧទ្ធរណ៍ទាំងនោះ។ យោងតាមដីកាកំណត់កាលបរិច្ឆេទដែលបានចេញនៅថ្ងៃនេះ សវនាការនេះនឹងត្រូវធ្វើឡើងនៅថ្ងៃទី២៧ ថ្ងៃទី២៨ និងថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩។

សំណៅជាសាធារណៈនៃដីកាកំណត់កាលបរិច្ឆេទសម្រាប់សវនាការនេះអាចរកមើលបាននៅលើគេហទំព័រ៖ https://www.eccc.gov.kh/sites/default/files/documents/courtdoc/%5Bdate-in-tz%5D/D266_12_KH.PDF

សហព្រះរាជអាជ្ញាជាតិ សហព្រះរាជអាជ្ញាអន្តរជាតិ និងសហមេធាវីជាតិ-អន្តរជាតិការពារក្តីជនត្រូវចោទនឹងមានសិទ្ធិលើកឡើងពីទឡ្ហីករណ៍របស់ខ្លួន។ ប្រសិនបើជនត្រូវចោទមានវត្តមាន ជនត្រូវចោទនឹងទទួលបានឱកាសដើម្បីធ្វើសេចក្តីសន្និដ្ឋានផ្ទាល់ខ្លួននៅពេលចុងបញ្ចប់បិទសវនាការ។

នៅពេលបិទបញ្ចប់សវនាការ អង្គបុរេជំនុំជម្រះនឹងធ្វើការពិចារណាដើម្បីចេញសាលដីកាសម្រេច។

ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌពោធិ៍សែនជ័យ ភ្នំពេញ ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ២៣-២១៩-៨១៤ ទូរសារ (៨៥៥) ២៣-២១៩-៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Porsenchey, PO Box 71, Phnom Penh, Cambodia Tel: (855) 023 219 814 Fax: (855) 023 219 841 Web: www.eccc.gov.kh

អង្គបុរេជំនុំជម្រះនៃ អ.វ.ត.ក មានសមាសភាពចៅក្រមជាតិចំនួនបីរូប និងចៅក្រមអន្តរជាតិចំនួនពីររូប។ ក្នុងនាមជាអង្គជំនុំជម្រះដោះស្រាយបណ្តឹងឧទ្ធរណ៍ អង្គបុរេជំនុំជម្រះ អាចបើកសវនាការលើសំណើ និងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកា និងសេចក្តីសម្រេចដែលចេញដោយសហចៅក្រមស៊ើបអង្កេត។

សវនាការនេះនឹងធ្វើឡើងជាសាធារណៈនៅពេលដែលចាប់ផ្តើមឧទ្ទេសនាមភាគីនៅក្នុងសំណុំរឿងជូនអង្គជំនុំជម្រះ នៅពេលដែលអង្គជំនុំជម្រះអានសេចក្តីរាយការណ៍អំពីសំណុំរឿងនេះ និងនៅពេល ចៅក្រមសួរសំនួរផ្សេងៗទៅកាន់ភាគី។ ក្រៅពីនេះ អង្គបុរេជំនុំជម្រះនឹងស្តាប់ទឡ្ហីករណ៍ពីភាគីនៅក្នុងសំណុំរឿងនៅក្នុងសវនាការសម្ងាត់វិញ។ បណ្តាញសារ ព័ត៏មាន នឹងត្រូវបានអនុញ្ញាតឲ្យថតរូបជាផ្លូវការ បន្ទាប់ពីបិទបញ្ចប់សវនាការ។

សម្រាប់ព័ត៏មានបន្ថែម សូមទាក់ទង៖

លោក នេត្រ ភក្ត្រា
ប្រធានផ្នែកកិច្ចការសាធារណ: និងជាអ្នកនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរសព្ទដៃលេខ៖ +៨៥៥ (0)១២ ៤៨៨ ១៥៦
អ៊ីមែល៖ neth.pheaktra@eccc.gov.kh